**ព្រះរាជាណាចក្រកម្ពុជា**

**ស្ថានឯកអគ្គរាជទូតកម្ពុជា ជាតិ សាសនា ព្រះមហាក្សត្រ**

**ប្រចាំសហព័ន្ធរុស្ស៊ី**

**ស្ថានតំណាងពាណិជ្ជកម្ម**

**លេខ 59/09-09 RCM**

**សូមគោរពជូន**

**ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**<u>កម្មវត្ថុ</u>** : របាយការណ៍ពាណិជ្ជកម្ម ខែ កក្កដា-សីហា ឆ្នាំ ២០០៩

សេចក្តីដូចមានក្នុងកម្មវត្ថុខាងលើ នាងខ្ញុំមានកិត្តិយសសូមគោរពរាយការណ៍ជូន ឯកឧត្តមទេសរដ្ឋមន្ត្រី មេត្តាជ្រាបអំពី ស្ថានភាពសេដ្ឋកិច្ចសហព័ន្ធរុស្ស៊ីនិងសកម្មភាពការងាររបស់ស្ថានតំណាងពាណិជ្ជកម្ម ខែ កក្កដា-សីហា ឆ្នាំ ២០០៩ នេះដូចតទៅ :

**I – ស្ថានភាពសេដ្ឋកិច្ចរុស្ស៊ី គួរកត់សំគាល់ក្នុង ខែ កក្កដា-សីហា ឆ្នាំ ២០០៩ នេះផ្តោតសំខាន់ទៅលើ :**

**១- <u>រុស្ស៊ី- WTO</u> :**

បច្ចុប្បន្ន យុទ្ធសាស្រ្តជាអាទិភាពនៃការចរចា រុស្ស៊ី- **WTO**គឺដឹកនាំការចរចារួមជាមួយប្រទេស **Kazakhstan Belarus**ក្នុងក្របខណ្ឌជាប្រទេសពន្ធរួម ហើយនិងចូលជាសមាជិក **WTO** ក្នុងលក្ខខណ្ឌដូចគ្នា និងក្នុងពេលតែមួយជាមួយគ្នា ។ ក្នុងករណីមានបញ្ហានិតិវិធីណាមួយកើតមានឡើង ការចូល **WTO** ត្រូវស្ថិតក្នុងរូបភាពទ្វេភាគីវិញ ដោយអនុវត្តការចុះហត្ថលេខាលើកិច្ចព្រមព្រៀងដោយឡែកពីគ្នា តែស្ថិតក្នុងលក្ខខណ្ឌនៃការចរចា **WTO**-ប្រទេសពន្ធរួម **Russia Kazak hstan Belarus** ។

ខែ សីហា ឆ្នាំ ២០០៩ បណ្តាប្រទេសពន្ធរួមមាន ប្រទេស **Russia Kazakhstan Belarus** បានបង្កើតក្រុមការងារចរចារ**WTO** រួមមួយ ដែលមានសមាជិកមានបទពិសោធន៍ចរចា មកពីបណ្តាប្រទេសទាំងបី និងដឹកនាំការចរចាដោយលោក **Maxim Medvedov** អនុរដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍សេដ្ឋកិច្ចរុស្ស៊ី ។ រុស្ស៊ីជឿជាក់ថា និងទទួលបានការគាំទ្រជាវិជ្ជមានពីប្រទេសអាមេរិកដែលនិងជំរុញអោយរុស្ស៊ីអាចចូល **WTO** ក្នុងពេលឆាប់ៗនេះ ។

បច្ចុប្បន្ន រុស្ស៊ីបានបញ្ចប់ការចរចាក្នុងក្របខណ្ឌក្រុមការងារ និងការចរចាបញ្ហាពន្ធ បញ្ហាដែលសេសសល់ត្រូវនៅដោះស្រាយស្ថិតក្នុងក្របខណ្ឌការងារនយោបាយ ។



17393Moscow, Str.Ak.Pilougina 14-3-781; Mobile: **7-926 457 89 64**; Email:**rcm_keo@hotmail.com**; Tel/Fax: **7-495 936 20 18**
Trade Representative MOC Moscow, Russian Federation August report/2009

ប្រទេស **Kazakhstan** ត្រូវបន្តការចរចាទ្វេភាគី និងបណ្តាប្រទេសចំនួន ២២ ទៀត និង ប្រទេស **Belarus** ជាមួយប្រទេសចំនួន ១០។

ក្នុងខែកក្កដា ឆ្នាំ ២០០៩ នេះ ក្នុងកិច្ចប្រជុំកំពូលប្រទេសអភិវឌ្ឍន៏ **G8** នៅប្រទេស **Italy** លោកប្រធានាធិបតីរុស្សុី **Dmitry Medvedov** បានថ្លែងអោយដឹងពីជំហ៊ររបស់រុស្សុីនិង **WTO** ថាការចូល **WTO** របស់រុស្សុីនិងធ្វើតាមរូបភាពទ្វេភាគី រុស្សុី- **WTO** ក្រោយពេលដែល រុស្សុី **Kazakhstan Belarus** បានសំរបសំរួលបទដ្ឋានគយរួមគ្នាហើយ។

ជំហ៊រថ្មីនេះ ផ្ទុយគ្នាពីការលើកឡើងដោយលោកនាយករដ្ឋមន្រ្តី **Vladimir Putin** កាលពីខែ មិថុនា ឆ្នាំ ២០០៩ ដែលថា រុស្សុីនិងបញ្ឈប់ការចរចាចូល **WTO** ក្នុងរូបភាពទ្វេភាគី ហើយធ្វើការចរចា និង ចូល **WTO** រួមជាមួយប្រទេស **Kazakhstan Belarus** ក្នុងក្របខណ្ឌជាប្រទេសពន្ធរួម។

ថ្នាក់ដឹកនាំរុស្សុីផ្សេងទៀតចាត់ទុកប្រតិកម្មខុសគ្នាដោយថ្នាក់ដឹកនាំកំពូលទាំងពីរជាការបំពេញអោយគ្នាទៅវិញទៅមក។

## ២-<u>ទីផ្សារៈ</u>

**ក្នុងទីផ្សារអង្ករ** ឆ្នាំ ២០០៩ នេះ បរិមាណនៃការនាំចេញអង្ករ កើនឡើងលើសការនាំចូល។ ខែមិថុនា ឆ្នាំ ២០០៩ រុស្សុីធ្វើការនាំចេញអង្ករចំនួន ១២៥០០តោន និងធ្វើការនាំចូលមានបរិមាណ ១១៨០០តោន។ ការផលិតអង្ករឆ្នាំ ២០០៩ កើនចំនួនពី ៣៤០-៣៥០ ពាន់តោន និងមានបរិមាណចំនួន ៦០% នៃតម្រូវការទីផ្សារ កំណើននេះនិងកើនដល់ចំនួន ៦% នៅចុងឆ្នាំ ២០០៩។

នៅពាក់កណ្តាលខែសីហា ឆ្នាំ ២០០៩ តំលៃអង្ករលេខ ១ ក្នុងទីផ្សារអន្តរជាតិធ្លាក់ចុះចំនួន ១២ដុល្លារអាមេរិកក្នុង ១តោន និងមានតំលៃចំនួនពី ៨៦៤ ទៅ ៨៥២ដុល្លារអាមេរិកក្នុងមួយតោន។

ក្នុងទីផ្សារអង្កររុស្សុី រុស្សុីធ្វើការនាំចូលអង្ករគ្រាប់វែងពីប្រទេស ចិន ឥណ្ឌា វៀតណាម ថៃ ។ តម្រូវការអង្ករទីផ្សារក្នុងស្រុកមានបរិមាណ ៦០០ ទៅ ៦៥០ពាន់តោន។ តំលៃអង្ករអាស្រ័យទៅលើបរិមាណនៃការនាំចូល និងការប្រែប្រួលនៃអត្រាប្រាក់រូប្លូ និងដុល្លារអាមេរិក និងមានតំលៃចំនួន ២៧៣០០ ទៅ ២៧៥២០ រូប្លូក្នុងមួយតោន (៨៥៥-៨៦០ ដុល្លារអាមេរិក)។ រុស្សុីមានគំរោងនិងតម្លើងពន្ធនាំចូលអង្ករក្នុងពេលខាងមុខនេះចំនួន ១៤០-១៥០ euros ក្នុងអង្ករចំនួន ១តោន។ មូលហេតុនៃការតម្លើងពន្ធនេះដោយសារការកើនឡើងនូវកំណើនទីផ្សារអង្ករ និងការផលិតអង្ករក្នុងស្រុក មួយវិញទៀតបទពិសោធន៏នៃការតម្លើងពន្ធអង្ករខែមិនា ឆ្នាំ ២០០៩ កន្លងមកជាបទពិសោធន៏ ធ្វើអោយរុស្សុីទទួលបានតុល្យភាពរវាងអង្ករនាំចូល និងអង្ករផលិតក្នុងស្រុក។ ហើយរុស្សុីជឿជាក់ផងដែរថា ដោយបញ្ហាការខកខានចូលជាសមាជិក **WTO** ក៏អាចផលប្រយោជន៏ជាច្រើនដល់រុស្សុីក្នុងការគ្រប់គ្រងបានល្អការផលិតក្នុងស្រុកទប់ស្កាត់និងការប្រកួតប្រជែងពីទំនិញនាំចូល។



17393Moscow, Str.Ak.Pilougina 14-3-781; Mobile: **7-926 457 89 64**; Email:**rcm_keo@hotmail.com**; Tel/Fax: **7-495 936 20 18**
Trade Representative MOC Moscow, Russian Federation

វិធានការការពារទីផ្សារអង្ករុស្ស៊ីបច្ចុបន្ន ធ្វើអោយអង្ករទីផ្សាររុស្ស៊ីមានឧត្តមភាពប្រកួតប្រជែងខ្ពស់បំផុតជាងទីផ្សារនាំចូល វិធានការនេះធ្វើកាត់បន្ថយភាពអាស្រ័យលើការនាំចូល ។ តាមការប៉ាន់ស្មានការនាំចូលអង្ករ ឆ្នាំ២០០៩ និងមានចំនួនមិនលើសពី ២០០ ទៅ ២២០ពាន់តោន កំណើនផលិតកម្មក្នុងស្រុកនិងកើនពីចំនួន ៣៤០-៣៥០ពាន់តោន ។

បច្ចុប្បន្ន ពន្ធនាំចូលអង្កររុស្ស៊ីមានទឹកប្រាក់ចំនួន **៧0 euros** ក្នុងអង្ករចំនួន ១តោន ។ ខែ កុម្ភៈ-មិនា រុស្ស៊ីបង្កើនពន្ធនាំចូលអង្ករលើកទី ១ ដល់ ចំនួន **១៦0 euros** ក្នុងអង្ករចំនួន ១តោន ការបង្កើនពន្ធលើកទី ២ ក្នុងខែកក្កដា ឆ្នាំ ២០០៩ មានចំនួន **១២0 euros** ក្នុងអង្ករចំនួន ១តោន ។

**ទីផ្សារសំលៀកបំពាក់** ថ្មីៗនេះបញ្ហាវិបត្តិហិរញ្ញវត្ថុនៅតែជាបញ្ហាចាក់ស្រេះក្នុងទីផ្សាររុស្ស៊ី ទោះបីថាបច្ចុប្បន្នតំលៃប្រេងឥន្ធនៈរុស្ស៊ីទទួលបាននៃកំណើនល្អប្រសើរក៏ចំណូលដែលទទួលបាននូវមិនទាន់គ្រប់គ្រាន់និងធ្វើការទូទាត់បំណុលក្រៅប្រទេស ។ ដូច្នេះហើយឧស្សាហកម្មផលិត និងទីផ្សារលក់សំលៀកបំពាក់ក្នុងស្រុក នៅមិនទាន់ទទួលបានការគាំទ្រឥណ្ឌទាន ផលិតកម្ម និងទីផ្សារ ។ជាមួយគ្នានេះដែរ អត្រាល៉ើងចុះរវាងប្រាក់ដុល្លារ និងរូប្ល ការបាត់បង់នូវ អតិថិជនរួមជាមួយការតំល៉ើងថ្លៃហាង ក៏នៅតែជាបញ្ហាធ្វើអោយទីផ្សារខោអាវប្រណិតជាច្រើនត្រូវបិទទ្វារ ។

បញ្ហាគួរកត់សំគាល់ ក្នុងឱកាសនៃវិបត្តិ បច្ចុប្បន្ន អ្នកផលិត និងនាំចូល កាត់បន្ថយពីការផលិត និងនាំចូលសំលៀកបំពាក់មកធ្វើការនាំចូលជាស្បែកជើងនិង **Accessories** ជាច្រើនទៅក្នុងហាង **Supermarket** និង **Hypermarket** ដែលទីផ្សារទីនោះទទួលបាននូវទាក់ទាញពីអតិថិជនជាច្រើន ។

### ៣-ការនាំចេញ-នាំចូលៈ

ក្នុងឆមាសទី ២ ឆ្នាំ ២០០៩ ទំហំពាណិជ្ជកម្មរុស្ស៊ីមានទឹកប្រាក់ចំនួន 208,300លានដុល្លារអាមេរិក ធ្លាក់ចុះចំនួន ៤៤.១% ធៀបរយៈពេលដដែលឆ្នាំ ២០០៨ ក្នុងនោះ ការនាំចេញ ធ្លាក់ចុះ ចំនួន ៤៦.៨% មានទឹកប្រាក់ចំនួន 126 ពាន់លានដុល្លារអាមេរិក ការនាំចូលធ្លាក់ចុះចំនួន ៣៩.៣% មានទឹកប្រាក់ចំនួន 82,300លានដុល្លារអាមេរិក ។

សមតុល្យពាណិជ្ជកម្មមាន 43,600លានដុល្លារអាមេរិក ( ឆមាសទី ១ ឆ្នាំ ២០០៨ មាន 101,100លានដុល្លារអាមេរិក) ។

ការផ្លាស់ប្តូរពាណិជ្ជកម្មនិងបណ្តាប្រទេសមិនមែនអតីតសហភាពសូវៀតថយចុះចំនួន ៤៥.១% មានទឹកប្រាក់ចំនួន 167,653លានដុល្លារអាមេរិក ក្នុងនោះជាមួយនិងបណ្តាប្រទេសសហភាពអឺរ៉ុបធ្លាក់ចុះចំនួន ៤៨.៧% ។

ទំនិញនាំចេញធ្លាក់ចុះមាន ថាមពលអគ្គីសនី ៥០.៣% ប្រេងកាត ៥២.៥% ឧស្ម័ន ៥០.៩% លោហធាតុ ៤៦.៩% ។

ដោយឡែកការនាំចេញគ្រាប់ធញ្ញជាតិកើនចំនួន ៧ដង និងមានបរិមាណចំនួន ៧០១៩លានតោន និងមានទឹកប្រាក់ចំនួន ១១៧០លានដុល្លារអាមេរិក ។



17393Moscow, Str.Ak.Pilougina 14-3-781; Mobile: **7-926 457 89 64**; Email:**rcm_keo@hotmail.com**; Tel/Fax: **7-495 936 20 18**
Trade Representative MOC Moscow, Russian Federation August report/2009

ការផ្លាស់ប្តូរពាណិជ្ជកម្មនិងបណ្តាប្រទេសអតីតសហភាពសូវៀតថយចុះចំនួន ៤៥.៤% មានទឹកប្រាក់ចំនួន 19 6,347លានដុល្លារអាមេរិក ។

## II – សកម្មភាពស្ថានតំណាងពាណិជ្ជកម្ម :

### ១_ទំនាក់ទំនងស្ថាប័នរុស្ស៊ី:

ថ្ងៃទី ៧ ខែ កក្កដា ឆ្នាំ ២០០៩ ជួបធ្វើការនិងលោក **Nikolay Popov** នាយករង្គទីនាយកដ្ឋានអាស៊ីនៃក្រសួងអភិវឌ្ឍន៍សេដ្ឋកិច្ចរុស្ស៊ី ។ គោលបំណងជំនួប សំណេះសំណាល និងស្វែងយល់ពីបញ្ហានាំចូលត្រី និងផលិតផលសមុទ្រទៅរុស្ស៊ី ។ លោក **Popov** បានអោយដឹងថា ការនាំចូលផលិតផលខាងលើ ទទួលបន្ទុកដោយស្ថាប័នសេវាកម្មសហព័ន្ធដែលហៅកាត់ថា **Rosselhoznadzor** ។ ការនាំចូលត្រូវអោយឆ្លើយតបទៅនិងបច្ចេកទេសនៃការវិចខ្ចប់ ការដឹកជញ្ជូន គុណភាព ដូចដែលមានចែងក្នុងសេចក្តីសំរេចលេខ **១៣-៨-០១/ ២-៨** ចុះថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ១៩៩៩ ដូចមានប្រែសំរួលក្រោផ្លូវការជូនភ្ជាប់មកជាមួយ ហើយការងារលំអិតផ្សេងទៀតនិងអាចស្វែងយល់តាមគេហទំព័រ **www.fsvps.ru** ។

**Veterinary and sanitary requirements within the import into Russian Federation of food fish, sea fish and their products, having passed terminal treatment**
**(Confirmed by the Ministry of agricultural products of the RF, the 23d of December, 1999 N 13-8-01/2-8)**

To the import into the Russian Federation are permitted fish, cooled fish, breezed fish, sea food and their products, witch have passed terminal treatment, related to man,s food, produced in enterprises, having a license of central State veterinary service of the country-exporter, concerning the delivery of exported production and controlled permanently by it.

Fish and sea food products are produced in enterprises (including floating bases), situated in administrative territories, available from African pig,s plague – during 3 last years and animal's fever – during 12 last months.

Sea fish and freshwater and sea food must be studied by the state veterinary service of the country-exporter for discovering helminthes, bacterial and virus infection using methods, applied in the country-exporter. After detecting helminthes, not exceeding admissible norm, fish must be disinfected using existing methods.

Fish and sea food have not received fodder, containing raw material, obtained by using methods of genetic enginery and other genetic modified sources.

To the import into Russian Federation are not permitted breezed fish and sea food:
- having the temperature inside of product, exceeding minus 18 degree Calcium:
- having seeds of salmonella or exciters of other bacterial infections;
- treated by colored substances, ion treatment or ultraviolet rays;
- having modifications, characteristic for infectious illness;
- off-grade in relation to organilepthical indexes;



17393Moscow, Str.Ak.Pilougina 14-3-781; Mobile: **7-926 457 89 64**; Email:**rcm_keo@hotmail.com**; Tel/Fax: **7-495 936 20 18**
Trade Representative MOC Moscow, Russian Federation

- submitted to deforestation within storage;
- Treated by colored and fragrant substances, ion treatment or ultraviolet rays.

Within veterinary and sanitary examination sea fish and freshwater fish, seafood and their products must be admitted as useful for man,s food and must not contain natural or synthetic estrogenetical, hormonal substances, tireostatic preparations, antibiotics pesticides and other medical substances.

Microbiological, chemical toxicological and radiological indexes of fish and sea food must be in correspondence to veterinary and sanitary regulations and requirements, valid in Russian Federation.
Tara and packing material must be using only once and conform to hygienic requirements.
Transports are treated and prepared in conformity to the rules, adopted in the country-exporter.
Execution of the conditions, indicated in present requirements, is du to be confirmed by the veterinary certificate, signed by the state veterinary doctor of the country-exporter and dressed in Russian language.
The shipping into Russian Federation of the production which had not been submitted to thermic treatment is possible only after obtaining by importer a license of the Veterinary Department of the Ministry of Agriculture of Russia. The Veterinary Department of the Ministry of Agriculture of Russia is entitled with proper veterinary specialists to realize the attestation of floating bases and enterprises, treating fish, confirming the possibility of delivery of production into Russian Federation./.

ថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០០៩ ជួបសំណេះសំណាលនិងពិភាក្សាការងារនិងលោកស្រី **Irina Sorokina** អនុប្រធាននាយកដ្ឋានទំនាក់ទំនងសេដ្ឋកិច្ចអន្តរជាតិនៃក្រសួងឧស្សាហកម្ម និងពាណិជ្ជកម្ម ។ គោលបំណងជំនួប ភ្ជាប់ទំនាក់ទំនង ប្តូរពត៌មានស្តីពីបញ្ហាការធ្វើពាណិជ្ជកម្មក្រៅប្រទេសនៅរុស្ស៊ី ។ ក្នុងឱកាសជំនួប លោកស្រី **Irina Sorokina** បានអោយដឹងថា :

-ប្រជាជនរុស្ស៊ី និងជនបរទេសមានសិទ្ធស្មើគ្នាក្នុងការធ្វើពាណិជ្ជកម្មក្រៅប្រទេសនៅរុស្ស៊ី ។ សិទ្ធនៃការធ្វើពាណិជ្ជកម្មអាចនិងត្រូវបានកម្រិតដោយយោងតាមច្បាប់អន្តរជាតិសហព័ន្ធរុស្ស៊ី និងច្បាប់រុស្ស៊ីផ្សេងទៀត

- ការធ្វើពាណិជ្ជកម្មនាំចេញ-នាំចូលមិនមានកំណត់បរិមាណ អាចនិងធ្វើការកំណត់លុះត្រាតែមានច្បាប់ហាមឃាត់

**ក្នុងករណីខ្លះរដ្ឋាភិបាលរុស្ស៊ី អាចកំណត់បរិមាណទំនិញនាំចេញ-នាំចូល ដោយសារ :**

-ការកំណត់បរិមាណទំនិញនាំចេញ-នាំចូល បណ្តោះអាសន្នដើម្បីចៀសវាងឱនភាពផ្សារក្នុងស្រុក

-ការកំណត់ការនាំចូលផលិតផលកសិកម្ម ធ្វើឡើងដើម្បីកាត់បន្ថយផលិតកម្ម និងការលក់ផលិតផលស្រដៀងគ្នា

-ការកំណត់ការធ្វើពាណិជ្ជកម្មក្រៅប្រទេសអាចនិងធ្វើឡើងដើម្បីឆ្លើយតបទៅនិងវិធានការគម្រាមកំហែងផលប្រយោជន៏រុស្ស៊ី ដោយជនបរទេស

**ចំពោះការធ្វើពាណិជ្ជកម្ម រុស្ស៊ី-កម្ពុជា រុស្ស៊ីមិនមានការកំណត់បរិមាណ និងធ្វើការហាមឃាត់ឡើយ លុះត្រាតែទំនិញនោះធ្វើអោយប៉ះពាល់ដល់សុវត្ថិភាព សុខភាព មនុស្ស និង សត្វ ។**

**-ការនាំចូលរុស្ស៊ី ត្រូវធ្វើឡើងដោយគោរពតាម វិធានការ ភូគ្គាមអនាម័យ និងវិធានការ ការពារការនាំចូលផ្សេងៗ ។**

**២-<u>ទំនាក់ទំនងសហគ្រាសរុស្ស៊ី:</u>**



17393Moscow, Str.Ak.Pilougina 14-3-781; Mobile: **7-926 457 89 64**; Email:**rcm_keo@hotmail.com**; Tel/Fax: **7-495 936 20 18**
Trade Representative MOC Moscow, Russian Federation 

ថ្ងៃទី ១៤ ខែ សីហា ឆ្នាំ ២០០៩ ជួបធ្វើការងារនិង លោក **Sergey Volkov** តំណាងក្រុមហ៊ុន រុស្ស៊ី **OJSC “INTER RAO UES** ពិភាក្សាពីបញ្ហានៃការកសាងវារីអគ្គីសនីនៅស្ទឹងត្រែង ដោយលោកបានទទួលពត៌មានថា ការដ្ឋាននេះ គាំងដំណើរការ ម្ចាស់គំរោងកំពុងស្វែងរកដៃគូរចូលរួមការផលិត ។ នាងខ្ញុំបានទំនាក់ទំនងទៅក្រសួងឧស្សាហកម្ម និងទទួលបានពត៌មានស្របគ្នា និងភាគីរុស្ស៊ីដែរ ហើយនៅតំណាច់ឆ្នាំ ២០០៩ នេះ និងមានតំណាងក្រសួងឧស្សាហកម្មមកទស្សនកិច្ចរុស្ស៊ី ភាគិរុស្ស៊ីសុំអោយនាងខ្ញុំជួយសំរួលជំនួប ។

**៣-ទំនាក់ទំនងស្ថានទូតបរទេសៈ**

ថ្ងៃទី ២០ ខែ សីហា ឆ្នាំ ២០០៩ ជួបសំណេះសំណាលជាមួយនិងលោកស្រី **Nguyen Hong Bac** ទីប្រឹក្សាពាណិជ្ជកម្មអមស្ថានទូតវៀតណាមនៃសាធារណរដ្ឋសង្គមនិយមវៀតណាមប្រចាំសសព័ន្ធរុស្ស៊ី ។គោលបំណងជំនួបពង្រឹងទំនាក់ទំនងការងារ ផ្លាស់ប្តូរពត៌មាន និងបទពិសោធន៍ទៅវិញទៅមក ។ ក្នុងឱកាសជំនួបលោកស្រីបានជំរាបអោយដឹងពីបញ្ហាការនាំចូលផលិតផលសមុទ្រ ក្នុងនោះមានការនាំចូល ត្រីប្រា ដែលជាផ្សារសំខាន់បំផុតរបស់វៀតណាមទៅរុស្ស៊ីដែលក្នុងមួយឆ្នាំមានបរិមាណចំនួន ៥០០០ ទៅ ៧០០០តោន ។ ឆ្នាំ ២០០៩ នេះ ដោយសាររុស្ស៊ីធ្វើការបឹទកាននាំចូលពីប្រទេស ចិន និង អឺរ៉ុបមួយចំនួន វៀតណាមគ្រោងធ្វើការនាំចូលត្រីប្រាទៅរុស្ស៊ីចំនួន ១លានតោន ។ ទីផ្សារផលិតផលសមុទ្ររុស្ស៊ីជួបការលំបាកច្រើនដោយរុស្ស៊ី តែងបឹទការនាំចូលដោយសារបញ្ហា ការវិចខ្ចប់ និងអនាម័យ ។ លោកស្រីបានជំរាបអោយដឹងពីស្ថាប័នរុស្ស៊ីដែលត្រូវទំនាក់ទំនង ។

**៤-ការចូលរួមកម្មវិធីផ្សេងៗ :**

ថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ២០០៩ ចូលរួមការតាំងពីព័រណ៍ផលិតផលទីផ្សារឆ្នាំ ២០១០ ដែលមានឈ្មោះ **Collection Premiere Moscow** មានប្រទេសចំនួន ២០ និងសាខាក្រុមហ៊ុនធំៗជាច្រើនចូលរួម ។ ក្រុមហ៊ុនទាំងនោះ ជាក្រុមហ៊ុនសំលៀកបំពាក់ប្រណិតមានយីហោធំៗ និងមានទិសដៅដំណើរការសំរាប់ទីផ្សាររុស្ស៊ី ។

អាស្រ័យដូចបានរៀបរាប់ខាងលើសូម ឯកឧត្តមទេសរដ្ឋមន្ត្រី មេត្តាជ្រាបជារបាយការណ៍ដ៏ខ្ពង់ខ្ពស់ ។

សូម ឯកឧត្តមទេសរដ្ឋមន្ត្រី មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់បំផុត អំពីនាងខ្ញុំ ។

**មូស្គូ. ថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០០៩**

**ទីប្រឹក្សាពាណិជ្ជកម្ម**

**កែវ មុន្នីធីតា**



17393Moscow, Str.Ak.Pilougina 14-3-781; Mobile: **7-926 457 89 64**; Email:**rcm_keo@hotmail.com**; Tel/Fax: **7-495 936 20 18**
Trade Representative MOC Moscow, Russian Federation

**<u>ចម្លងជូន</u>**

-លោកជំទាវខុទ្ទកាល័យឯកឧត្តមទេសរដ្ឋមន្ត្រី

-ឯកឧត្តមរដ្ឋលេខាធិការ

-ឯកឧត្តមអនុរដ្ឋលេខាធិការ

-ឯកឧត្តមអគ្គនាយក " ដើម្បីជ្រាបជារបាយការណ៍ "

-ឯកសារ-កាលប្បវត្តិ



17393Moscow, Str.Ak.Pilougina 14-3-781; Mobile: **7-926 457 89 64**; Email**:rcm_keo@hotmail.com**; Tel/Fax: **7-495 936 20 18**
Trade Representative MOC Moscow, Russian Federation